ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ អង្គារ ៣ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ១១ ខែ កុម្ភៈ ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ស្តីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ឆ្នាំ ២០១៩

នាព្រឹកថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើ "**វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ សម្រាប់ ឆ្នាំ ២០១៩**" ដោយបានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងអំឡុងខែ កញ្ញា ឆ្នាំ ២០១៨ និងបានក្លាយជាឯកសារមូលដ្ឋានដែលឆ្លុះបញ្ចាំងនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា និងជាមូលដ្ឋានដ៏រឹងមាំក្នុងការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍតាមវិស័យនានា ដើម្បីឆ្ពោះទៅសម្រេចបាននូវបង្គោលចរ ឆ្នាំ ២០៣០ និងចក្ខុវិស័យ ឆ្នាំ ២០៥០ ដែលកម្ពុជារំពឹងថានឹងប្រែក្លាយខ្លួនទៅជាប្រទេសអភិវឌ្ឍន៍ ។

ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ បានរៀបចំក្របខ័ណ្ឌតាមដានសមិទ្ធកម្ម ដោយផ្អែកលើទ្រឹស្តីនៃបរិវត្តកម្ម (Theory of Change), ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រចតុកោណ និងបានកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indictors - KPIs) សម្រាប់តាមដានវឌ្ឍនភាពនៃការអនុវត្ត ។ សូចនាករសមិទ្ធកម្មគន្លឹះចែកចេញជា ០៣ កម្រិត រួមមាន÷ ១. កម្រិតយុទ្ធសាស្ត្រ សំដៅលើគោលដៅ ឬបច្ច័យនៃការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច (impact), ២. កម្រិតចតុកោណយុទ្ធសាស្ត្រ គឺជាលទ្ធផលចុងក្រោយ (final outcome) និង ៣. កម្រិតមុំ ឬជ្រុងនៃចតុកោណយុទ្ធសាស្ត្រ គឺជាលទ្ធផលបន្ទាប់ (immediate outcome) ។ ក្របខ័ណ្ឌតាមដានសមិទ្ធកម្មមានសូចនាករគន្លឹះសម្រាប់វាស់វែងមាន ១៩៤ ដែលមានទាំងសូចនាករបែបបរិមាណ (quantitative) និងសូចនាករបែបគុណភាព ហើយបានកំណត់នូវបន្ទាត់មូលដ្ឋាន (baseline) និង គោលដៅ (targets) សម្រាប់វាស់បម្រែបម្រួលវឌ្ឍនភាពតាមឆ្នាំនីមួយៗ ព្រមទាំងមានស្ថាប័នទទួលបន្ទុកការអនុវត្តជាក់លាក់ ។

ជារួម, ការអនុវត្ត**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** សម្រាប់ឆ្នាំ ២០១៩ ទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ពោលគឺភាគច្រើននៃសូចនាករគន្លឹះត្រូវបានសម្រេចតាម និងលើសគោលដៅដែលបានកំណត់ ។ ជាក់ស្តែង,

វឌ្ឍនភាពនៃសូចនាករកម្រិតយុទ្ធសាស្ត្របានង្ហាញថា គោលដៅ **“កំណើន”** សម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៧,១% តាមការគ្រោងទុក ដែលឆ្លុះបញ្ចាំងតាមរយៈការបន្តកើនឡើងនៃទំហំវិនិយោគ, អត្រាអតិផរណាដែលស្ថិតក្នុងកម្រិតគ្រប់គ្រងបាន និងល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាដើម ។ ជាមួយគ្នានេះ, គោលដៅ “**ការងារ**” ក៏ស្ថិតក្នុងស្ថានភាពប្រសើរ តាមរយៈការបន្តកើនឡើងនៃចំនួនការងារថ្មី, ចំនួនកម្លាំងពលកម្មជំនាញ, អត្រាចូលរួមរបស់កម្លាំងពលកម្ម និងទំហំមន្ត្រីរាជការស៊ីវិលដែលអាចគ្រប់គ្រងបាន ។ បន្ថែមលើនេះ, គោលដៅ “**សមធម៌**” ក៏សម្រេចបានលទ្ធផលប្រសើរផងដែរ ពោលគឺការរក្សាបាននូវអត្រានៃភាពក្រីក្រស្ថិតក្រោមកម្រិត ១០%, វិសមភាពចំណាយ (មេគុណជីនី “Gini coefficient”) ស្ថិតក្នុងកម្រិតទាប និងការកើនឡើងនៃអត្រាចំនួនស្ត្រីក្នុងស្ថាប័នរដ្ឋ ។ ចុងក្រោយ, គោលដៅ **“ប្រសិទ្ធភាព”** ក៏មានវឌ្ឍនភាពល្អបង្គួរ ផងដែរ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំបានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានខិតខំ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** និងលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តគាំទ្រ និងផ្តល់កិច្ចសហការ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ត និងការរាយការណ៍ពីវឌ្ឍនភាព**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី ៤** បន្តទៀត។